ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១១ សស.សរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងរៀបចំកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក (FATCA)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង រៀបចំកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់សហរដ្ឋអាមេរិក (FATCA) ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ជា ចាន់តូ** | អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- លោកជំទាវ **នាង ច័ន្ទថាណា** | អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោកជំទាវ **ខូន សុខា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៥- ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម **ឱក ម៉ុង** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- ឯកឧត្តម **ស៊ា កុសល** | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨- លោកជំទាវ **ខៀង សុផានី** | អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ៩- លោកជំទាវ **ជា សិរី** | អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១០- ឯកឧត្តម **ម៉ី អ៊ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១- ឯកឧត្តម **ភៅ ថាច** | អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក។ |

**ប្រការ ២.~**

ក្រុមការងារអន្តរក្រសួងនេះមានតួនាទី-ភារកិច្ច ដូចតទៅ ៖

- សិក្សាស្វែងយល់ឱ្យស៊ីជម្រៅអំពីខ្លឹមសារ និងនីតិវិធីនៃការចរចាជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់សហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងជម្រើសគំរូម៉ូដែលនៃកិច្ចព្រមព្រៀងការអនុវត្តអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក (FATCA)
- ពិនិត្យនិងសិក្សាពីសង្គតិភាពនៃអភិក្រមច្បាប់ជាតិ និងភាពខ្វាស់គ្នានៃក្របខ័ណ្ឌច្បាប់ ដែលកំពុងអនុវត្តនៅប្រទេសកម្ពុជា
- រៀបចំប្រមូលព័ត៌មាននិងទិន្នន័យទាំងឡាយណា ដែលជាគុណប្រយោជន៍ដល់ការអនុវត្តអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់សហរដ្ឋអាមេរិក (FATCA)
- កំណត់ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់សហរដ្ឋអាមេរិក
- ពិនិត្យនិងដោះស្រាយនូវរាល់បញ្ហាប្រឈម ដែលកើតមានក្នុងការអនុវត្តអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់អាមេរិក (FATCA)
- រៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់សហរដ្ឋអាមេរិក សំដៅបម្រើផលប្រយោជន៍រួមរបស់ប្រជាជននៃរដ្ឋទាំងពីរ *និង*
- ជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការកំណត់ ដឹកនាំ អនុវត្ត និងតាមដានការអនុវត្តអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់សហរដ្ឋអាមេរិក (FATCA) ។

**ប្រការ ៣.-**

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាននិងសមាជិកត្រូវចូលរួមប្រជុំឬចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមានឬមានធុរៈ ។

ក្នុងករណីប្រធានអវត្តមាន ក្រុមការងារនេះអាចដំណើរការប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន ឬរបស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន ។

**ប្រការ ៤.-**

ក្នុងពេលប្រជុំ ប្រធានអង្គប្រជុំមានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំឬមន្ត្រីជំនាញក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមប្រជុំឬបំភ្លឺអង្គប្រជុំតាមការចាំបាច់ ។ ប្រធានអង្គប្រជុំក៏មានសិទ្ធិអញ្ជើញតំណាងវិស័យឯកជន និងតំណាងដៃគូអភិវឌ្ឍន៍ផ្សេងទៀតចូលរួមប្រជុំ ក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍ តាមការចាំបាច់ ។

**ប្រការ ៥.-**

ក្រុមការងារអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយនៅធនាគារជាតិនៃកម្ពុជា ជាសេនាធិការសម្រាប់បំពេញមុខងាររបស់ខ្លួន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ដែលជាប្រធានក្រុមការងារអន្តរក្រសួងនេះ ។

ក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ធនាគារជាតិនៃកម្ពុជា សម្រាប់ដំណើរការការងាររបស់ខ្លួន ។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
  រាជកិច្ច
- ឯកសារ-កាលប្បវត្តិ